**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខ : ១៥៣៤/២០ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ១រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០២០

# របាយការណ៍
# វឌ្ឍនភាពការងារប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២០
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## ១.សេចក្តីផ្តើម

ក្នុងខែកញ្ញា ឆ្នាំ ២០២០ ទោះបីជានៅមានការរាតត្បាតនៃមេរោគកូវីដ១៩នៅតាមបណ្តាប្រទេសជាច្រើនក្នុងលោកក៏ដោយ ក៏ប្រទេសកម្ពុជានៅតែរក្សាបានការមិនឆ្លងចូលក្នុងសហគមន៍ដដែល ។ ប្រការនេះ ជាកាលានុវត្តភាពសម្រាប់រាជរដ្ឋាភិបាល និងវិស័យឯកជនមានឱកាស បំពេញការងារដោយពេញលេញឡើងវិញ ដោយគ្រាន់តែគោរពតាមបទដ្ឋានអនាម័យរបស់ក្រសួងសុខាភិបាលឲ្យបានត្រឹមត្រូវប៉ុណ្ណោះ ។ ការអភិវឌ្ឍជនបទបាន និងកំពុងជួយដល់ប្រជាជនជនបទ ក្នុងការស្តារឡើងវិញនូវសេដ្ឋកិច្ចគ្រួសារក៏ដូចជាជីវភាពប្រចាំថ្ងៃ តាមរយៈការផ្តល់សេវាសាធារណៈ មួយចំនួនដូចជាការតភ្ជាប់ផ្លូវគមនាគមន៍ក្នុងតំបន់ជនបទមកកាន់ទីផ្សារ សាលារៀន មណ្ឌលសុខភាព និងមជ្ឈមណ្ឌលសេវាដទៃទៀតក្នុងទូទាំងប្រទេសដើម្បីបង្កើនសកម្មភាពពាណិជ្ជកម្មឡើងវិញ រួមទាំងសេវាទឹកស្អាត និងមូលដ្ឋានអនាម័យជនបទផងដែរ ។ មួយវិញទៀត ក្រសួងបានរៀបចំអង្គវិបស្សនានៅខេត្តកំពតស្តីពីការរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២១-២០៣០ ដែលបានកំណត់ចក្ខុវិស័យ និងគោលនយោបាយច្បាស់លាស់ព្រមទាំងផែនការសកម្មភាពជាច្រើន សំដៅប្រែក្លាយជនបទកម្ពុជា ជាសង្គមជនបទស៊ីវិល័យនៅឆ្នាំ ២០៣០ ដែលបង្ហាញពីភាពរុងរឿងរបស់ប្រជាជនជនបទទាំងផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ក្រោមការដឹកនាំប្រកបដោយកិត្យានុភាព និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

លទ្ធផលដែលក្រសួងសម្រេចបានប្រចាំខែកញ្ញា ឆ្នាំ២០២០ នេះមានដូចខាងក្រោម៖

## ២.វឌ្ឍនភាព

### ២.១. លទ្ធផលរួមរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

ការអនុវត្តផែនការសកម្មភាពទូទាំងប្រទេសសម្រេចបានប្រមាណជា ៧៥% នៃផែនការសកម្មភាពប្រចាំឆ្នាំ ២០២០ គិតមកដល់ចុងខែកញ្ញានេះ ។



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីម៉ែល dap.mrd@gmail.com

## ២.២.លទ្ធផលរបស់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ

### ២.២.១.ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ ២០២០ មន្រ្តីរាជការក្របខណ្ឌសរុបមានចំនួន ១ ៥១៨ នាក់ (ស្រី ៤១១ នាក់) ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែសីហា គឺមិនមានការប្រែប្រួលទេ។ ក្រសួងបានទទួលលិខិតចូលចំនួន ១៣១ ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១១៧ ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ១២ ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ១៦១ ច្បាប់ ។

### ២.២.២.ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែកញ្ញា នេះក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០២០ សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៣ ៣៩២ ១៩៨ ១៣៣ រៀលស្មើនឹង២,៣៨% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ៤៣ ៧២៤ ១៤៦ ២០០ រៀលស្មើនឹង ២៣,០១% នៃច្បាប់ថវិកា ។

### ២.២.៣. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ជួបប្រជុំជាមួយធនាគារអភិវឌ្ឍន៍អាស៊ីតាមប្រព័ន្ធអនឡាញ ស្តីពីការអនុវត្តផែនការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើសូចនាករគោលដៅចំនួន ០៥ ដែលផ្តោតលើការបញ្ចូលភាពគ្រីក្រ យេនឌ័រ ក្នុងផែនការយុទ្ធសាស្ត្រថវិកា (BSP) ការធ្វើសមាហរន្តកម្មថវិកាវិនិយោគជាមួយថវិកាចរន្តក្នុងផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្ត FMM, FMIS, ICT Audit និងការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មជាសាធារណៈ ។

### ២.២.៤. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- ចូលរួមកិច្ចប្រជុំលើកទី ១៨ នៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ប្រារព្ធនៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ** ។

### ២.២.៥. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ

- រៀបចំអង្គវិបស្សនាស្តីពីការរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ ២០២១-២០៣០ ដើម្បីពិភាក្សាពីប្រធានបទចំនួន ០៣ គឺ "បញ្ហា ការប្រឈម និងកាលានុវត្តភាព" " ចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្រ្ត" និង "កម្មវិធីអាទិភាព" រយៈពេល០២ថ្ងៃ ដោយមានអ្នកចូលរួមចំនួន ១០០ នាក់ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្រ្តីក្រសួងអភិវឌ្ឍន៍ជនបទ** ។
- បានរៀបចំសិក្ខាសាលា ស្តីពីការស្វែងយល់ពីការងារអភិវឌ្ឍន៍ជនបទនៅមូលដ្ឋានលើប្រធានបទ បញ្ហា ការប្រឈម និងកាលានុវត្តភាពក្នុងការងារអភិវឌ្ឍន៍ជនបទ និងទស្សនកិច្ចសិក្សាគម្រោងអភិវឌ្ឍន៍ជនបទនៅខេត្តកំពង់ស្ពឺ ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តព្រះវិហារ

- តាមដានការអនុវត្តផែនការសកម្មភាពឆ្នាំ ២០២០ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកោះកុង
- បានចូលរួមកិច្ចប្រជុំចាប់ផ្តើមស្តីពីការរៀបចំយុទ្ធសាស្ត្រកសិកម្មអេឡិចត្រូនិកនៅកម្ពុជា នៅសណ្ឋាគាររីជីនស៊ីអង្គរ ខេត្តសៀមរាប
- បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការ Engineers Without Borders និងអង្គការ CWS
- បានផ្តល់លិខិតគាំទ្រកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការ Operation Hope Foundation
- បានផ្តល់លិខិតគាំទ្រសុំផ្លាស់ប្តូរស្លាកលេខរថយន្តចំនួន ០៤ គ្រឿង និងទោចក្រយានយន្តចំនួន ០៩ គ្រឿង ជូនអង្គការ អេហ្វ អេក កម្ពុជា
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ ។

**២.២.៦. ការងារអធិការកិច្ច និងសវនកម្ម**

- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៩-២០២០ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០៤ រួមមាន ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប
- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ២០១៩ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

**២.២.៧. ការងារអភិវឌ្ឍន៍ផ្លូវជនបទ និងមន្ទីរពិសោធន៍**

- គម្រោងថែទាំខួប ឆ្នាំ ២០២០ សរុបចំនួន ៣០ គម្រោង ស្មើនឹង ៥៧ ខ្សែ ប្រវែងសរុប ៤៦៣,៤២ គ.ម លូមូល ៦០ កន្លែង និងលូប្រអប់ ០២ កន្លែង សម្រេចលទ្ធផលគិតជាមធ្យមបាន ៩០%
- គម្រោងថែទាំប្រចាំ ឆ្នាំ ២០២០ សរុបចំនួន ៣៨ គម្រោង ស្មើនឹង ២៩៨ ខ្សែ ប្រវែងសរុប ២ ៨១៣,៧៤ គ.ម លូមូល ០១ កន្លែង និងស្លាកសញ្ញាចរាចរចំនួន ២ ១៥២ ស្លាក សម្រេចលទ្ធផលគិតជាមធ្យមបាន ៧៥%
- ការងារស្តាបនា កែលម្អ និងជួសជុល ឆ្នាំ ២០២០ មាន ៩៧ គម្រោង ប្រវែងសរុប ៧២៤,៩១ គ.ម សម្រេចបានលទ្ធផលជាមធ្យម ៦៦,១៩ %
- គម្រោងការងារជួសជុលបន្ទាន់ កំពុងដំណើរការឯកសារចំនួន ៤៣ គម្រោង សម្រេចលទ្ធផលគិតជាមធ្យមបាន ៧០% ។

### ២.២.៨. ការងារផ្គត់ផ្គង់ទឹកជនបទ

- សាងសង់ពាងត្រងទឹកភ្លៀងជាលក្ខណៈគ្រួសារចំណុះ ២៥០០ លីត្រ ចំនួន ១៤០ កន្លែង នៅខេត្តព្រៃវែង
- សាងសង់អណ្តូងអាហ្វ្រីដេវ ចំនួន ២៦ អណ្តូង នៅខេត្តកំពង់ធំ និងខេត្តសៀមរាប
- ជួសជុលអណ្តូងអាហ្វ្រីដេវ ចំនួន ៤០ អណ្តូង នៅខេត្តកំពង់ចាម និងខេត្តរតនគិរី។

### ២.២.៩. ការងារថែទាំសុខភាព និងអនាម័យជនបទ

- បានផ្តល់ចានបង្គន់តាមផ្ទះឯកជន ចំនួន ៥៥ ខ្នងផ្ទះ នៅខេត្តកែប និងខេត្តស្វាយរៀង
- បានអប់រំអនាម័យប្រជាពលរដ្ឋ ចំនួន ៣៨ នាក់ នៅខេត្តកំពង់ចាម
- បានចុះអប់រំផ្សព្វផ្សាយអនាម័យតាមសហគមន៍ ដោយផ្តោតសំខាន់លើអនាម័យលាងសម្អាតដៃដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ១៩
- បានបើកវគ្គបណ្តុះបណ្តាលស្តីពីការផ្ទៀងផ្ទាត់ភូមិ ODF នៅខេត្តកំពង់ឆ្នាំង ។

### ២.២.១០. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះពិនិត្យវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍភូមិ នៅខេត្តកំពង់ចាម និងខេត្តសៀមរាប
- ចុះពិនិត្យ និងតាមដានការអនុវត្តគម្រោងលើកកម្ពស់សន្តិសុខស្បៀងលក្ខណៈគ្រួសារ នៅខេត្តកែប
- ចុះពិនិត្យវគ្គបណ្តុះបណ្តាលស្តីពីការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ នៅខេត្តត្បូងឃ្មុំ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាល រយៈពេលខ្លី ចំនួន ០២ វគ្គ សិក្ខាកាម ៦៨ នាក់ ស្រី ៣៨ នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានបន្តធ្វើការផ្សព្វផ្សាយជ្រើសរើសសិស្សឲ្យចូលរៀនវគ្គបណ្តុះបណ្តាល ឆ្នាំ២០២០ ។

### ២.២.១១. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ៩៦ នាក់ ស្រី ១២ នាក់
- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ២០៥ នាក់ ស្រី ២៥ នាក់
- បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី "ការពង្រឹងសមត្ថភាព និងកសាងគុណតម្លៃដើម្បីការងារអភិវឌ្ឍន៍ជនបទ" នៅភោជនីយដ្ឋានទន្លេបាសាក់ II មានសិក្ខាកាមចូលរួមសរុបចំនួន ៦៧ នាក់ ស្រីមានចំនួន ០៩ នាក់
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំ និងគ្រប់គ្រងផែនការថវិកា" នៅខេត្តកំពង់ធំ មានសិក្ខាកាមចូលរួមសរុបចំនួន ៥៥ នាក់ ស្រីចំនួន ០៧ នាក់ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីអាហារូបករណ៍ ចំនួន ០៣ លើក ។
- មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១៣ ខេត្ត បានរៀបចំ និងកែសម្រួល

ឯកសារពាក់ព័ន្ធមួយចំនួន រៀបចំគម្រោងផែនការថវិកាសម្រាប់ឆ្នាំ២០២១ ព្រមទាំងបន្តការផ្អាកជាបណ្តោះអាសន្នលើការងារបណ្តុះបណ្តាល ដោយសារការបញ្ហាជំងឺកូវីដ-១៩ ។ ដោយឡែកសម្រាប់មជ្ឈមណ្ឌលចំនួន ០៧ ខេត្ត នៅក្នុងចំណោម ១៣ ខេត្ត មានមជ្ឈមណ្ឌលខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ នៅក្នុងខែកញ្ញា ឆ្នាំ ២០២០ នេះមជ្ឈមណ្ឌលបានបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាលរយៈពេលវែងមួយចំនួន និងបានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីចំនួន ២៤ វគ្គ មានសិក្ខាកាមសរុប ៥១២ នាក់ (ស្រី២៦០ នាក់) ក្នុងនោះ

- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានធ្វើការបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាល ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៣៥ នាក់ (ស្រី ៦៥ នាក់) លើមុខវិជ្ជាចំនួន ០៧
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង បានធ្វើការបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាល ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៨២ នាក់ (ស្រី ៦៤ នាក់) លើមុខវិជ្ជាចំនួន ០៤
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានធ្វើការបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាល ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៥០ នាក់ (ស្រី ២៤ នាក់) លើមុខវិជ្ជាចំនួន ០២
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានធ្វើការបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាល ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៧៥ នាក់ (ស្រី ៧៧ នាក់) លើមុខវិជ្ជាចំនួន ០៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានធ្វើការបើកបន្តឡើងវិញនូវវគ្គបណ្តុះបណ្តាល ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧០ នាក់ (ស្រី ៣០ នាក់) លើមុខវិជ្ជាចំនួន ០២ ។

### ២.២.១២. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពុងអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់បានផ្តល់ឥណទានសរុបចំនួន ៤ ២៦៥ ៩៥៨ ៥២៨ រៀល (បួនប៊ីលានពីររយហុកសិបប្រាំលានប្រាំបួនរយហាសិបប្រាំបីពាន់ប្រាំរយម្ភៃប្រាំបីរៀល) ស្មើនឹង ១ ០៨៥ ៧១៥,៥៩ ដុល្លារអាមេរិក (មួយលានប៉ែតសិបប្រាំពាន់ប្រាំពីររយដប់ប្រាំដុល្លារនិងហាសិបប្រាំបួនសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ២១០ នាក់ នៅភូមិគោលដៅចំនួន ១៩១ ភូមិ ៧៤ ឃុំ ៣៣ ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥។

### ២.២.១៣. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- បានចូលរួមអបអរសាទរ ពិធីលើកស្លាកទីស្នាក់ការ ជនជាតិដើមភាគតិចចំនួន ០២ សហគមន៍ នៅភូមិប៉ាអរ ឃុំលុងឃុង ស្រុកបរកែវ និងភូមិជួយអំពិល ឃុំចាអ៊ុង ស្រុកអូរជុំ ខេត្តរតនគិរី
- បានចូលរួមសំណេះសំណាលសួរសុខទុក្ខ ចែកសាប៊ូអនាម័យ និងដាំកូនឈើ ក្នុងឱកាសនៃការប្រារព្ធទិវាជនជាតិដើមភាគតិចពិភពលោកលើកទី២៦ និងលើកទី១៦ សម្រាប់ប្រទេសកម្ពុជា នៅខេត្តឧត្តរមានជ័យ ។

**២.២.១៤.ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**

ក្នុងខែកញ្ញា ឆ្នាំ ២០២០ នេះ លេខាធិការដ្ឋានក្រុមការងារចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលសំណើ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានចំនួន ០៧ ករណី ក្នុងនោះតាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រសួងដោះស្រាយបានចំនួន ០២ ករណី ។

**២.២.១៥. ការងារយេនឌ័រ**

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីសមត្ថភាពយេនឌ័រ និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ ២០១៩-២០២៣
- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីផលប៉ះពាល់នៃកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា៖ ភាពងាយរងគ្រោះ ភាពក្រីក្រ និងយេនឌ័រ ។

**២.២.១៦. ការងារប្រយុទ្ធនឹងជំងឺអេដស៍**

- ប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០២០ ។

**២.៣. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី**

**២.៣.១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២**

គិតត្រឹមដំណាច់ខែកញ្ញានេះ គម្រោងសម្រេច៖

- បានបញ្ចប់ការសាងសង់ផ្លូវ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលមានប្រវែងសរុប ៥៦១,៣០ គ.ម
- បានបញ្ចប់ការសាងសង់ប្រឡាយទឹកស្រោចស្រពដំណាំ និងមណ្ឌលសុខភាព នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១០៤,០៨ គ.ម សម្រេចបាន ៨៥,២០%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៧៨,៩៦%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ ខ្សែ មានប្រវែងសរុប ១២៦,៣០ គ.ម សម្រេចបាន ៨៣,៤២%
- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៨៧,៥៩%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ ខ្សែ ប្រវែង ១១៣,៤០ គ.ម សម្រេចបាន ៩១,៥៩% ។

**២.៣.២. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងបានទទួលការអនុម័តចំនួន ១ ២៨៤ គម្រោង ប្រវែង ១ ១៤៨ ៤៧៨ ម៉ែត្រ បាន និងកំពុងអនុវត្តចំនួន ៨៦៥ គម្រោង ប្រវែង ៧៨៧ ១៩៥ ម៉ែត្រ ក្នុងខេត្តគោលដៅចំនួន ១៧ ក្នុងនោះ បានបញ្ចប់ការងារ ចំនួន ២១០ គម្រោង ប្រវែង ១៩៣ ៩៧៩ ម៉ែត្រ ។

### ២.៣.៣.គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡានឆាង ( Mekong Lancang Cooperation )

- រៀបចំឯកសារសម្រាប់អនុវត្តផែនការសកម្មភាពជំហានទី២

### ២.៣.៤. គម្រោងសហប្រតិបត្តិការមេគង្គ-គង្គា

- កំពុងដាក់ស្នើថវិកាជំហានទី២ ។

### ២.៣.៥. គម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍

គិតត្រឹមខែកញ្ញានេះ គម្រោងសម្រេច៖

- បាន និងកំពុងសាងសង់ផ្លូវ ចំនួន ០៧ ខ្សែ ប្រវែង ៤៩,៨៩គីឡូម៉ែត្រ នៅខេត្តកណ្តាល ដោយសម្រេចបាន ១៤,៤០%
- បានបញ្ចប់ និងផ្ញើរបាយការណ៍វាយតម្លៃផ្លូវកញ្ចប់ទី ៣ សម្រាប់ការសាងសង់ផ្លូវប្រវែង ១៥៩ គីឡូម៉ែត្រ នៅក្នុងខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តសៀមរាប ជូនធនាគារពិភពលោក ដើម្បីសុំការឯកភាព
- កំពុងធ្វើការវាយតម្លៃឯកសារដេញថ្លៃជ្រើសរើសក្រុមហ៊ុនសម្រាប់ការងារ Institutional Strengthening and Capacity Building for Disaster Resiliency of Rural Roads ។

### ២.៣.៦. គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ជំហាន ២

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ជំហាន២ អនុវត្តរយៈពេល ១២ខែ ក្រោមហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលក្នុងនោះគម្រោងផ្គត់ផ្គង់ទឹកជនបទអនុវត្តនៅខេត្តគោលដៅចំនួន ១០ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម និងគម្រោងកែលម្អផ្លូវជនបទ ជំហាន ២ អនុវត្តនៅខេត្តគោលដៅចំនួន ០៦ រួមមាន ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ។ នៅក្នុងខែកញ្ញានេះ គម្រោងសម្រេច៖

- ជីកអណ្តូងបានចំនួន ៤៤ អណ្តូង
- តម្លើងស្នប់ ចំនួន ៦៣ ស្នប់
- បាន និងកំពុងសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ១១៩,៥៥ គ.ម នៅខេត្តគោលដៅទាំង ០៦ សម្រេចបាន ២៨,៦៩ % ។

### ២.៣.៧. គម្រោងពិពិធកម្មកសិកម្មកម្ពុជា

គម្រោងពិពិធកម្មកសិកម្មកម្ពុជាអនុវត្តរយៈពេល ០៦ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ។ គម្រោងមានគោលបំណង ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍខ្សែច្រវ៉ាក់ផលិតផលកសិកម្មចម្រុះ នៅក្នុងតំបន់ភូមិសាស្ត្រ នៅខេត្តគោលដៅចំនួន ១៣ រួមមាន រាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តក្រចេះ និងខេត្តកំពង់ឆ្នាំង ។នៅក្នុងខែកញ្ញានេះគម្រោងសម្រេច៖

- បានជ្រើសរើសទីប្រឹក្សាផ្នែកហិរញ្ញវត្ថុ

- បានផ្សព្វផ្សាយជាលើសទី២ ដើម្បីជ្រើសរើសទីប្រឹក្សាបច្ចេកទេសផ្នែកលទ្ធកម្ម
- បានចូលរួមប្រជុំពិនិត្យខ្លឹមសារផ្សព្វផ្សាយដើម្បីជ្រើសរើសក្រុមគោលដៅចំនួន ០៣ លើក
- បានទទួលការឯកភាពពីធនាគារពិភពលោកលើខ្លឹមសារ TOR សម្រាប់ជ្រើសរើសទីប្រឹក្សាបច្ចេកទេសការងារសាងសង់ផ្លូវ ។

**២.៣.៧. គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា**

គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា(CSLEP) ជាគម្រោងក្រោមហិរញ្ញប្បទានឥណទានសហប្រតិបត្តិការ ពីធនាគារពិភពលោក និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ០៥ ឆ្នាំ (២០២០-២០២៥) ។ គម្រោងមានគោលបំណងស្ដាបនាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST និងប្រភេទផ្លូវបេតុង នៅខេត្តគោលដៅចំនួន ០៧ រួមមាន ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ ។ ក្នុងខែកញ្ញានេះគម្រោងសម្រេចបាន ៖

- បាន និងកំពុងរៀបចំធ្វើបញ្ជីទ្រព្យសកម្មរយៈពេលវែង
- បានរៀបចំ និងធ្វើរបាយការណ៍ផែនការថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំ ២០២០ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានបង្កើតសៀវភៅណែនាំស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ
- បានរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាល ស្ដីពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងប្លង់គណនីគម្រោង នៅសណ្ឋាគារភ្នំពេញ
- បានចុះសិក្សាខ្សែផ្លូវតាមតំបន់គោលដៅនៅខេត្តចំនួន ០៥ មានដូចជាខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តសៀមរាប ។

## ៣. ទិសដៅបន្ត

### ៣.១. បញ្ហាប្រឈម

- ការផ្លាស់ប្ដូរទម្លាប់របស់ប្រជាជនក្នុងការប្រតិបត្តិអនាម័យល្អ ត្រូវការពេលវេលា
- សមត្ថភាពចូលរួមផ្ដល់សេវារបស់វិស័យឯកជននៅមានកម្រិត
- តំបន់ខ្លះខ្វះទឹកដែលអាចប៉ះពាល់ដល់ស្ថានភាពអនាម័យ
- ទម្លាប់សង្គមក្នុងការបន្ទោរបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកស្អាត និងការលាងដៃឲ្យបានត្រឹមត្រូវ ខ្វះការយល់ដឹង ដែលនាំឲ្យកម្រិតវិនិយោគពីគ្រួសារទាប
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល ការផ្គត់ផ្គង់បរិក្ខារអនាម័យ)
- ការចូលរួមរបស់សហគមន៍ក្នុងការសម្រេចចិត្តលើការងារអភិវឌ្ឍន៍នៅមានកម្រិត
- ប្រជាពលរដ្ឋនៅតាមមូលដ្ឋានមួយចំនួនមានជីវភាពខ្វះខាត ជាហេតុនាំឲ្យមានការធ្វើចំណាកស្រុកទៅប្រកបមុខរបរនៅប្រទេសជិតខាង ដែលធ្វើឲ្យប៉ះពាល់ដល់ដំណើរការនៃការអនុវត្តសកម្មភាពអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួន
- គ.អ.ភ ពុំមានស្នាក់ការសម្រាប់ធ្វើការងារ
- ស្ថាប័នឬអង្គការមួយចំនួនមិនបានប្រើប្រាស់ គ.អ.ភ ហើយបានបង្កើតជនបង្គោលផ្សេងៗពី គ.អ.ភ

- កិច្ចសហការជាមួយអង្គការ ដៃគូអភិវឌ្ឍន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានីខេត្ត នៅមានកម្រិតនៅឡើយលើវិស័យឥណទានជនបទ និងសកម្មភាពបង្កើនប្រាក់ចំណូលផ្សេងៗ ។

**៣.២. ទិសដៅតាមអង្គភាព**

- បន្តរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២១-២០៣០ របស់ក្រសួងលើជំពូកទី៣ ស្តីពី ការដឹកនាំ ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងជំពូកទី៤ ស្តីពី សេចក្តីសន្និដ្ឋាន
- ចុះតាមដានសកម្មភាពអង្គការមិនមែនរដ្ឋាភិបាល
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាល
- បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ
- បន្តជំរុញការងារតាមការដ្ឋានសាងសង់ផ្លូវ ដើម្បីបញ្ចប់ការងារឲ្យបានទាន់ពេលវេលា
- បន្តចុះត្រួតពិនិត្យការងារស្ថាបនា និងកែលម្អផ្លូវជនបទ
- អនុវត្តការងារថែទាំ និងជួសជុលផ្លូវនៅតាមបណ្តាខេត្ត
- បន្តការងារបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ ទូទាំង ២៥ រាជធានី ខេត្ត
- ផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- បន្តការរៀបចំផែនការ និងកិច្ចសហការនានាជាមួយអង្គការដៃគូនានាលើកម្មវិធីលើកកម្ពស់អនាម័យជនបទ
- បន្តសហការសាកល្បងការផ្ទេរមុខងារអនាម័យទៅរដ្ឋបាលថ្នាក់ស្រុកទាំង ១៥ ក្នុងខេត្តគោលដៅទាំង ០៣ គឺខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង
- សិក្សាស្រុកគោលដៅថ្មី និងរៀបចំឯកសារគតិយុត្តិសម្រាប់ស្រុកចំនួន ១៥ ដែលត្រូវសាកល្បងផ្ទេរមុខងារអនាម័យ
- ត្រៀមរៀបចំពិនិត្យសារឡើងវិញនូវផែនការសកម្មភាពជាតិជំហានទី១ (២០១៤-២០១៨) និងរៀបចំធ្វើផែនការសកម្មភាពជាតិជំហានទី២ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ (២០១៩-២០២៣)
- បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នពាក់ព័ន្ធដើម្បីបញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី
- បន្តជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យបង្កើតសហគ្រាសខ្នាតគ្រួសារ និងខ្នាតតូច
- ពង្រឹងការផ្តល់សេវាជូនប្រជាពលរដ្ឋដូចជាការងារឥណទានសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ ការបណ្តុះបណ្តាលបំនិនជីវិត ការរកទីផ្សារសម្រាប់ផលិតផលជនបទជាដើម
- សិក្សាភូមិគោលដៅដើម្បីរៀបចំកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច
- បន្តការចុះកំណត់អត្តសញ្ញាណ បទបញ្ញាផ្ទៃក្នុង និងលក្ខន្តិកៈរបស់ក្រុមជនជាតិដើមភាគតិច ។

## ៤.សេចក្តីសន្និដ្ឋាន

លទ្ធផលសម្រេចបានក្នុងខែកញ្ញានេះ មានវឌ្ឍនភាពល្អប្រសើរ ដោយអង្គភាពនីមួយៗអាចដំណើរការសកម្មភាពបានឡើងវិញយ៉ាងសកម្ម តែត្រូវអនុវត្តវិធានការនានាតាមការណែនាំរបស់ក្រសួងសុខាភិបាលដើម្បីបញ្ចៀសការឆ្លងជំងឺកូវីដ១៩ ក្នុងនោះរួមមាន ការងារជួសជុល ថែទាំផ្លូវជនបទ ជីកស្រះទឹក សាងសង់អណ្តូងទឹក សាងសង់បង្គន់អនាម័យ ការអភិវឌ្ឍន៍សហគមន៍ ។ ចំពោះកិច្ចសហការជាមួយដៃគូ និងអង្គការមិនមែនរដ្ឋាភិបាលដំណើរការដោយរលូន ។ ការរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២១-២០៣០ ដោយក្រុមការងារបច្ចេកទេសទាំងពីរ "កគសជ" និង "កសពជ" ក្រោមធំត្រ "គរគ" បាន និងកំពុងដំណើរការដោយរលូន តាមផែនការដែលបានគ្រោងទុក ៕

**រដ្ឋមន្ត្រី**

បណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន**